ស្ថានភាពជាសាកលនៃការធ្វើពាណិជ្ជកម្មផ្នែកជីវបច្ចេកវិទ្យា/ការគ្រប់គ្រងដំណាំដាំដុះ៖ ២០១៣

ដោយ **Clive James,** អ្នកផ្តួចផ្តើម និងជាប្រធាន **ISAAA**

*សូមឧទិសចំពោះអ្នកដែលទទួលជ័យ លាភីណូបែលសន្តិភាព (Nobel Peace Laureate) លើកក្រោយ គឺលោក Norman Borlaug ដែលជាអ្នកផ្តួចផ្តើមបង្កើត ISAAA,*
*ក្នុងឱកាសនៃខួបកំណើតទី១០០របស់លោកនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤*

---

## ចំណុចសំខាន់ចំនួន១០ស្តីអំពីជីវបច្ចេកវិទ្យា/ការគ្រប់គ្រងដំណាំដាំដុះ៖ ២០១៣

**ចំណុចសំខាន់ទី១. ឆ្នាំ២០១៣ ជាឆ្នាំទី១៨នៃការធ្វើពាណិជ្ជកម្មប្រកបដោយភាពជោគជ័យផ្នែកដំណាំដាំដុះបែបជីវបច្ចេកវិទ្យា។**
ដំណាំដាំដុះបែបជីវបច្ចេកវិទ្យាគឺជាការធ្វើពាណិជ្ជកម្មលើកតំបូងនៅឆ្នាំ១៩៩៦។ ចំនួនហិចតានៃដំណាំបែបជីវបច្ចេកវិទ្យាមានការកើនឡើងជារៀងរាល់ឆ្នាំនៅចន្លោះឆ្នាំ១៩៩៦ដល់២០១៣ ជាមួយនឹងអត្រានៃការកើនឡើងទ្វេរដងក្នុងរយះពេល១២ឆ្នាំ
បានបង្ហាញអំពីទំនុកចិត្តនិងការជឿជាក់លើហានិភ័យពីសំណាក់កសិកររាប់លាននាក់ទាំងនៅប្រទេសកំពុងអភិវឌ្ឍន៍និងប្រទេសឧស្សាហ៍កម្មនៅលើពិភពលោក។ គួរអោយកត់សម្គាល់ថា តាំងពីការដាំដំណាំនេះជាលើកតំបូងនៅឆ្នាំ១៩៩៦មក វាជាការដែលមិននឹកស្មានដល់ ដែលថាចំនួនដាំដុះមានការកើនឡើងជាង១,៥កោដហិចតាដែលបានដាំដុះប្រកបដោយជោគជ័យ ហើយចំនួននេះមានដល់ទៅ៥០%លើសផ្ទៃដីដ៏មហិមា នៃប្រទេសចិន ឬសហរដ្ឋអាមេរិក។

**ចំណុចសំខាន់ទី២. ចំនួនហិចតានៃដំណាំជីវបច្ចេកវិទ្យាបានកើនឡើងជាង១០០ដង ពី១,៧លានហិចតានៅឆ្នាំ១៩៩៦ ដល់ជាង១៧៥លានហិចតានៅឆ្នាំ២០១៣។** អ្វីដែលធ្វើអោយ ដំណាំជីវបច្ចេកវិទ្យាមានការទទួលយកយ៉ាងឆាប់បំផុតនូវបច្ចេកវិទ្យាដាំដុះនាពេលថ្មីៗនេះ គឺដោយសារពួកគេបានទទួលផល។ នៅឆ្នាំ២០១៣ ផ្ទៃដីដំណាំជីវបច្ចេកវិទ្យាបានកើនឡើងចំនួន៥លានហិចតា ជាមួយនឹងអត្រាកំណើនប្រចាំឆ្នាំចំនួន៣%ជារៀងរាល់ឆ្នាំ។ វាជាការសំខាន់ក្នុងការកត់សម្គាល់ថាគំរូនៃការកើនឡើងប្រចាំឆ្នាំ និងការបន្តរពង្រីក ផ្ទៃដីបន្ថែម អាចធ្វើការសន្និហ្ឋត់ថានៅរយះពេលពី រឬបីឆ្នាំខាងមុខទៀតការីកចម្រើននៃអត្រា(ពី៩០%ទៅ១០០%)ទទួលយកគោលការណ៍ដាំដុះជីវបច្ចេកវិទ្យាអាចដល់កម្រិតមួយដែលសល់ផ្ទៃដីតិចតួច ឬអស់រលីងមិនអាចពង្រីកទៅទៀតបាន។

**ចំណុចសំខាន់ទី៣. ចំនួនប្រទេសដែលកំពុងដាំដុះដំណាំជីវបច្ចេកវិទ្យា និងអត្រានៃការបរាជ័យ។** ក្នុងចំណាម២៧ប្រទេសដែលបានដាំដំណាំជីវបច្ចេកវិទ្យានៅក្នុងឆ្នាំ២០១៣ មាន១៩ជាប្រទេសកំពុងអភិវឌ្ឍន៍ និង៨ជាប្រទេសឧស្សាហ៍កម្ម។ អត្រានៃការបរាជ័យគឺ៤៧,១លានហិចតា ឬស្មើនឹង២៧%។

**ចំណុចសំខាន់ទី៤. ជំហ៊ានទីពីរនៅឆ្នាំ២០១៣ ប្រទេសកំពុងអភិវឌ្ឍន៍បានធ្វើការដាំដុះច្រើន ហិចតាជាប្រទេសឧស្សាហ៍កម្ម។** គួរអោយកត់សម្គាល់ថា ប្រទេសកំពុងអភិវឌ្ឍន៍បានដាំដំណាំជីវបច្ចេកវិទ្យាដល់ទៅ៥៤%(៩៤លានហិចតា) ច្រើនជាងប្រទេសឧស្សាហ៍កម្មដែលដាំតែ៤៦%(៨១លានហិចតា)នៃដំណាំជីវបច្ចេកវិទ្យាសរុបនៅឆ្នាំ២០១៣។ ជោគជ័យនៃភាពជាដៃគូរ រវាងវិស័យសាធារណៈនិងឯកជនបានបង្កើតឡើងនៅបណ្តាលប្រទេសមួយចំនួនដោយរួមបញ្ចូលប្រទេសBrazil, Bangladesh និង Indonesia។

**ចំណុចសំខាន់ទី៥. ចំនួនកសិករដែលបានដាំដំណាំជីវបច្ចេកវិទ្យា។** នៅក្នុងឆ្នាំ២០១៣ ស្ថិតិបានបង្ហាញអោយឃើញថាមានកសិករចំនួន១៨លាននាក់ ដែលចំនួននេះមានការកើនឡើង០,៧លាននាក់ជាងកាលពីឆ្នាំ២០១២ដែលបានដាំដំណាំជីវបច្ចេកវិទ្យា និងត្រូវបានកត់សម្គាល់ឃើញថា លើស៩០% ឬជាង១៦,៤លាននាក់ដែលជាគ្រួសារក្រីក្រមានធនធានតូចតាចនៅក្នុងប្រទេសកំពុងធ្វើការអភិវឌ្ឍន៍។ កសិករគឺជាអ្នកគ្រប់គ្រងលើហានិភ័យ និងបង្កើនផលិតភាពតាមរយៈ ការធ្វើអោយប្រសើឡើងប្រកបដោយនិរន្តភាព(ការអភិរក្សការដាំដុះត្រឹម១,៥កោដហិចតានៃដីដាំដុះ ដោយការរក្សាព្រៃឈើ និងការធ្វើជីវចម្រុះ)។ នៅក្នុងឆ្នាំ២០១៣ ស្ថិតិបានបង្ហាញថាមានគ្រួសារកសិករចំនួន៧,៥លាននាក់នៅប្រទេសចិន និង៧,៣លាននាក់ទៀតនៅប្រទេសឥណ្ឌា បានសម្រេចចិត្តដាំកម្បាសនៅលើផ្ទៃដីជាង១៥ហិចតា ដោយសារដំណាំនេះផ្តល់អត្ថប្រយោជន៍ច្រើនបែបច្រើនយ៉ាង។ នៅក្នុងឆ្នាំ២០១៣ មានកសិករជិត៤០០០០០នាក់នៅប្រទេស Philippines បានទទួលផលប្រយោជន៍ពីដំណាំពោតតាមបែបជីវបច្ចេកវិទ្យា។

**ចំណុចសំខាន់ទី៦. ប្រទេសជាប់ចំណាត់ថ្នាក់ចំនួន៥ដែលដាំដំណាំជីវបច្ចេកវិទ្យា ការត្រៀមរៀបចំជាលើកទីតំបូងដើម្បីទប់ទល់នឹងភាពរាំងស្ងួតលើដំណាំពោត និងការបរាជ័យរបស់ដំណាំសណ្តែកសៀង។** សហរដ្ឋអាមេរិកនៅតែបន្តរជាប្រទេសនាំមុខគេ ជាមួយនឹងផ្ទៃដី៧០,១លានហិចតា ដែលជាមធ្យមប្រហែលជា៩០%បានទទួលយកការដាំដុះដំណាំគ្រប់ប្រភេទ។ វាជាការសំខាន់ ដែលដំណាំពោតតាមបែបជីវបច្ចេកវិទ្យាដែលបានទប់ទល់ជាមួយភាពរាំងស្ងួតជាលើកទីតំបូង

ត្រូវបានដាំដុះដោយកសិករអាមេរិកចំនួន២០០០នាក់ នៅលើផ្ទៃដី៥០០០០ហិចតា។ Brazilជាប្រទេសចំណាក់ថ្នាក់ទីពីរ និងទី៥នៅឆ្នាំបន្ទាប់មកទៀតដែលជាម៉ាស៊ីននៃការរីកចម្រើនជាសាកល និងមានការរីកចម្រើនផ្ទៃដីដាំដុះដំណាំជីវបច្ចេកវិទ្យាច្រើនជាងប្រទេសដទៃទៀត ជាមោទនភាព និងការកត់សម្គាល់ឃើញថាមានការកើនឡើង៣,៧លានហិចតា ដែលមានចំនួន១០%លើសពីឆ្នាំ២០១២ ហើយចំនួននោះសម្រេចដល់៤០,៣លានហិចតា។ Brazilក៏ជាប្រទេសតំបូងគេដែលបានដាំនិងជួបបរាជ័យលើដំណាំសណ្តែកសៀង តែវាក៏ជាចំណុចចាប់ផ្តើមប្រកបដោយជោគជ័យជាមួយនឹងផ្ទៃដី២,២លានហិចតា ដែលជាប្រភពនៃដំណាំជីវបច្ចេកវិទ្យាដែលមានលក្ខណ:ធន់នឹងវីរុសសម្រាប់ការធ្វើពាណិជ្ជកម្ម។ ប្រទេសArgentinaនៅតែជាប្រទេសទី៣ជាមួយនឹងផ្ទៃដី២៤,៤លានហិចតា។ ប្រទេសIndia បានចូលខ្លួនមកជំនួសប្រទេសCanadaដែលជាប្រទេសទី៤ មានការដាំដុះដំណាំកប្បាសលើផ្ទៃដី១១លានហិចតា ជាមួយការអត្រាទទួលយកដល់ទៅ៩៥%។ Canadaជាប្រទេសទី៥ដោយមានការថយចុះការដាំដុះមកនៅត្រឹម១០,៨លានហិចតា ប៉ុន្តែនៅរក្សាអត្រាទទួលយកខ្ពស់ដល់ទៅ៩៦%។ នៅឆ្នាំ២០១៣នេះ ប្រទេសជាប់លំដាប់ថ្នាក់ទាំង៥បានដាំបន្ថែមលើសពី១០លានហិចតាដើម្បីធ្វើការនាំចេញ និងជាមូលដ្ឋានដ៏រឹងមាំសម្រាប់ការលូតលាស់នាពេលអនាគត។

**ចំណុចសំខាន់ទី៧. ស្ថានភាពដំណាំជីវបច្ចេកវិទ្យានៅអាហ្វ្រិក។**

ផ្ទៃដីដ៏ធំល្វឹងល្វើយនៅអាហ្វ្រិកខាងត្បូងនៅបន្តការរីកលូកលាស់ដោយសារដំណាំជីវបច្ចេកវិទ្យាអស់រយ:ពេលជាងមួយទស្សវត្សមកហើយ។ ទាំងBurkina និងSudan បានពង្រីកការដាំកប្បាសរបស់ខ្លួនលើផ្ទៃដីរៀងៗខ្លួនរាប់សឺបហិចតាគួរអោយភ្ញាក់ផ្អើរពី៥០%ទៅ៣០០% នៅឆ្នាំ២០១៣។ ប្រទេសចំនួន៧(Cameroon, Egypt, Ghana, Kenya, Malawi, Nigeria, និង Uganda)បានធ្វើការសាកល្បងដល់ជំហ៊ានចុងក្រោយមុននឹងដល់ការអនុញ្ញាតអោយធ្វើពាណិជ្ជកម្ម។ វាជាការសំខាន់ ដែលគម្រោងWEMAគ្រោងនឹងធ្វើការចែកចាយជីវបច្ចេកវិទ្យា ស្តីពីការដាំពោតដោយធន់នឹងភាពរាំងស្ងួតជាលើកតំបូងនៅអាហ្វ្រិកនៅឆ្នាំ២០១៧នេះ។ កង្វះខាតផ្នែកវិទ្យាសាស្រ្ត ពេលវេលា ថវិការ និងប្រព័ន្ធច្បាប់សម្របនឹងបន្តទៅជាបញ្ហាចម្បងក្នុងការទទួលយក។ ការទទួលខុសត្រូវ ការប្រយ័ត្នប្រយែងដែលមិនធ្វេសប្រហេស និងច្បាប់ពិតជាត្រូវការចាំបាច់ ជាពិសេសចំពោះប្រទេសដែលកំពុងអភិវឌ្ឍន៍តូចតាច។

**ចំណុចសំខាន់ទី៨. ស្ថានភាពដំណាំជីវបច្ចេកវិទ្យានៅអឺរ៉ុប។** ប្រទេសនៅអឺរ៉ុបចំនួន៥ដែលបានដាំដំណាំពោតបែបជីវបច្ចេកវិទ្យាលើផ្ទៃដី១៤៨០១៣ហិចតា ដែលស្មើនឹងប្រមាណ១៥%នៅឆ្នាំ២០១២។ ប្រទេស Spainជាប្រទេសនាំមុខនៅអឺរ៉ុបជាមួយនឹងដំណាំពោតលើផ្ទៃដី១៣៦៩៦២ហិចតា ដែលស្មើនឹង១៨% ហើយតាមរបាយការណ៍ អត្រាទទួលយកមាន៣១%នៅឆ្នាំ២០១៣។

**ចំណុចសំខាន់ទី៩. អត្ថប្រយោជន៍ដែលបានផ្តល់ដោយដំណាំជីវបច្ចេកវិទ្យា។** តាំងពីឆ្នាំ១៩៩៦ដល់២០១២ ដំណាំជីវបច្ចេកវិទ្យាបានចូលរួមចំណែកដល់សន្តិសុខស្បៀង និរន្តភាព និងបរិស្ថាន/បម្រែបម្រួលអាកាសធាតុដោយបង្កើនផលិតផលកសិកម្មមានតម្លៃស្មើ១១៦,៩កោដUS$(ដុល្លារអាមេរិក), ធ្វើអោយប្រសើរឡើងនូវបរិស្ថានដោយសន្សំ៤៩៧លានគីឡូក្រាមនៃការប្រើថ្នាំពុលសត្វល្អិត, ដោយគ្រាន់តែឆ្នាំ២០១២មួយគត់ ការកាត់បន្ថយការបំពុលរបស់ឧស្ម័នកាបូនិច($CO_2$)បានចំនួន២៦,៧កោដគីឡូក្រាម ដែលស្មើនឹងការប្រើប្រាស់រថយន្តចំនួន១១,៨លានគ្រឿងនៅលើដងផ្លូវក្នុងរយ:ពេលមួយឆ្នាំ, ការអភិរក្សជីវចម្រុះដោយការសន្សំសំចៃលើផ្ទៃដី១២៣លានហិចតាពីឆ្នាំ១៩៩៦ដល់ឆ្នាំ២០១២, និងបានជួយក្នុងការកាត់បន្ថយភាពក្រីក្រដល់កសិករចំនួន១៦,៥លានគ្រួសារ និងសមាជិកគ្រួសាររបស់ពួកគេសរុប៦៥លាននាក់ ដែលជាអ្នកក្រីក្រជាងគេនៅលើពិភពលោក។ ដំណាំជីវបច្ចេកវិទ្យាមានសារសំខាន់ ប៉ុន្តែវាមិនល្អហើយមានភាពងាយស្រួលក្នុងការអនុវត្តការដាំដុះដូចដំណាំឆ្លាស់ និងដំណាំដែលមានភាពធន់នោះទេ វាទាមទារអោយមានការដាំដុះតាមបែបជីវបច្ចេកវិទ្យា យ៉ាងពិតប្រាកដដូចដែលគេបានធ្វើនាពេលកន្លងមក។

**ចំណុចសំខាន់ទី១០. និន្នាការនាពេលអនាគត។** យើងមានគំនិតសុទិដ្ឋិនិយមដោយប្រាកដប្រជាជាមួយនឹងគំរូទិដ្ឋភាពនៃការរីកចម្រើនប្រចាំឆ្នាំ និងអត្រានៃការទទួលយកដ៏ខ្ពស់ (៩០%ឬច្រើនជាងនេះ) គឺជាគោលការណ៍ដែលដំណាំជីវបច្ចេកវិទ្យាអាចឈានទៅរកភាព ចាស់ទុំលើទីផ្សារទាំងនៅប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសឧស្សាហកម្ម។ ប្រទេសBangladesh, Indonesia និងPanama បានអនុម័តយល់ព្រមអោយដាំដំណាំជីវបច្ចេកវិទ្យានៅ ក្នុងឆ្នាំ២០១៣ដើម្បីធ្វើការដាំដុះបែបពាណិជ្ជកម្មនៅក្នុងឆ្នាំ២០១៤។

ISAAA គឺជាអង្គការមិនមែនរដ្ឋាភិបាលដែលមានការគាំទ្រដោយស្ថាប័នសាធារណ: និងវិស័យឯកជន។ រាល់ការប៉ាន់ប្រមាណលើដំណាំជីវបច្ចេកវិទ្យាទាំងអស់ដែលបានផ្សព្វផ្សាយនៅរាល់ការបោះពុម្ពផ្សាយទាំងអស់របស់ ISAAA គឺជាការប៉ាន់ស្មាន វាជាការវាយតម្លៃអំពីលក្ខ័ណនានាដែលចូលរួមក្នុងការដាំដុះ។ សម្រាប់ព័តមានលម្អិតមាននៅក្នុង ISAAA លេខ៤៦ ស្ថានភាពសាកលនៃការធ្វើពាណិជ្ជកម្មផ្នែកជីវបច្ចេកវិទ្យា/ការគ្រប់គ្រងដំណាំដាំដុះ៖ ២០១៣ ដែលរៀបរៀងដោយ Clive James។ សម្រាប់ព័តមានបន្ថែម សូមមើលនៅក្នុង http://www.isaaa.org
ឬទាក់ទងមជ្ឈមណ្ឌល ISAAA អាស៊ីអាគ្នេយ៍ តាមរយ:ទូរស័ព្ទលេខ៖+63 49 536 7216 ឬអ៊ីមែល:info@isaaa.org